**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
**អគ្គនាយកដ្ឋានពន្ធដារ**
លេខ...៣៧០២......អពដ

L202501150394TD3418

ថ្ងៃ សុក្រ ៣ កើត ខែ មាឃ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៥

# សេចក្តីជូនដំណឹង
## ស្តីពី
## កម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ២០២៤

អនុលោមតាមបទប្បញ្ញត្តិនៃប្រការ ១៥ ជំពូកទី ៣ នៃប្រកាសលេខ ៥៧៥ សហវ.ប្រក.អពដ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០២៤ ស្តីពីពន្ធលើប្រាក់បៀវត្ស និងសេចក្តីណែនាំលេខ ៧០១៥ អពដ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២០ ស្តីពីការអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់កម្ចីដល់និយោជិត អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការកំណត់កម្រិតអត្រាការប្រាក់ទីផ្សារសម្រាប់ប្រាក់កម្ចីប្រចាំឆ្នាំ២០២៤ ដោយផ្អែកលើការគណនាមធ្យមភាគនៃមធ្យមភាគអត្រាការប្រាក់ឱ្យខ្ចីប្រចាំឆ្នាំរបស់ធនាគារពាណិជ្ជធំៗក្នុងស្រុកចំនួន ១២ (ដប់ពីរ) ដូចខាងក្រោម៖

- **៩,៦៧% ក្នុងមួយឆ្នាំ** ចំពោះប្រាក់រៀល
- **៨,៧៩% ក្នុងមួយឆ្នាំ** ចំពោះប្រាក់ដុល្លារអាមេរិក។

អគ្គនាយកដ្ឋានពន្ធដារសូមបញ្ជាក់បន្ថែមថា អត្រាការប្រាក់ខាងលើនេះប្រើប្រាស់ក្នុងគោលដៅអនុវត្តកាតព្វកិច្ចកាត់ទុកពន្ធលើអត្ថប្រយោជន៍បន្ថែមលើការផ្តល់ប្រាក់ឱ្យនិយោជិតខ្ចីតែប៉ុណ្ណោះ។

អាស្រ័យហេតុនេះគ្រប់អង្គភាពពន្ធដារ និងសហគ្រាសជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសទាំងអស់ត្រូវអនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះ ឱ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាពខ្ពស់។

**អគ្គនាយកដ្ឋានពន្ធដារ**

អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី (១១០) និង ម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855) 23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh